អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីថ្លែងការណ៍របស់ សហព្រះរាជអាជ្ញា

បន្ទាប់ពីបានធ្វើការពិចារណាដ៏ល្អិតល្អន់មក សហព្រះរាជអាជ្ញាបានសម្រេចថាប្តឹងឧទ្ធរណ៍តវ៉ាទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ដែលបានបញ្ជូនរឿងរបស់ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ **ឌុច** ទៅជំនុំ ជម្រះពីបទឧក្រិដ្ឋកម្មផ្សេងៗដែលបានប្រព្រឹត្តនៅក្នុងមន្ទីរស-២១ របស់*ខ្មែរក្រហម* នៅទីក្រុងភ្នំពេញ ។

ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន សហព្រះរាជអាជ្ញា យកចិត្តទុកដាក់ទៅលើការទន្ទឹងចង់បានរបស់ប្រជាជនកម្ពុជា និងរបស់សហគមន៍អន្តរជាតិ ដែលចង់ឲ្យមានការជំនុំជម្រះក្តីឲ្យបានយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន នូវជនទាំងឡាយដែលគេជឿថា បានប្រព្រឹត្តការរំលោភបំពានមួយចំនួនទៅលើច្បាប់មនុស្សធម៌អន្តរជាតិយ៉ាងធ្ងន់ធ្ងរបំផុត នៅក្នុងប្រវត្តិសាស្ត្រនៃសតវត្សរ៍ទី២០ ។

ទោះបីជាកិច្ចស៊ើបសួរអំពីឧក្រិដ្ឋកម្មរបស់ **ឌុច** ត្រូវបានដឹកនាំធ្វើដោយសហចៅក្រមស៊ើបអង្កេតនោះក៏ដោយ ក៏វាគឺជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថាករណីរឿងនោះ គឺហួសពីវិមតិសង្ស័យ ។ អាណត្តិកិច្ចរបស់សហព្រះរាជអាជ្ញា គឺមិនគ្រាន់តែធ្វើការចោទប្រកាន់ទៅលើបុគ្គលមួយចំនួនតែប៉ុណ្ណោះនោះទេ គឺថែមទាំងត្រូវធានាអំពីការរៀបចំឯកសារទាំងស្រុង និងប្រកបដោយការពិតនូវសាច់រឿងនៃឧក្រិដ្ឋកម្មទាំងឡាយរបស់ *ខ្មែរក្រហម* និងអំពីឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គលនៃជនទាំងឡាយ ដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ដើម្បីឲ្យសមស្របតាមគោលបំណងរបស់តុលាការនេះ។

តាមការវាយតម្លៃរបស់សហព្រះរាជអាជ្ញា ទោះបីជានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានលើកឡើងនូវបទចោទប្រកាន់ខ្លះដែលអាចធានាចំពោះការកាត់ទោស **ឌុច** យ៉ាងណាក៏ដោយ ក៏បទឧក្រិដ្ឋព្រមទាំងទម្រង់នៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌរបស់ **ឌុច** នៅមានកំរិត ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះមិនបានចោទប្រកាន់ **ឌុច** ឲ្យទទួលខុសត្រូវក្នុងនាមជា សហចារី ចំពោះឧក្រិដ្ឋកម្មសំខាន់ៗមួយចំនួន ដែលបានកើតឡើងដែលជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងមន្ទីរស-២១ នោះទេ ។ ការណ៍នេះអាចនឹងរារាំងមិនឲ្យអង្គជំនុំជម្រះសាលាដំបូង អាចកាត់សេចក្តី

ទៅលើគ្រប់បទល្មើសទាំងអស់ឲ្យបានពេញលេញ ដែលជាការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ ឌុច នៅមន្ទីរស-២១ នោះទេ ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ខកខានមិនបានចោទប្រកាន់ ឌុច នៅក្រោមក្រមព្រហ្មទណ្ឌរបស់កម្ពុជាឆ្នាំ១៩៥៦ សូម្បីតែច្បាប់លក្ខន្តិក:នៃ អ.វ.ត.ក បានផ្តល់យុត្តាធិការទៅលើបទល្មើសទាំងនេះដល់តុលាការនេះក៏ដោយ ។ ប្រសិនបើការចោទប្រកាន់បានធ្វើឡើងក្រោមក្រមព្រហ្មទណ្ឌនេះ គឺបានឆ្លុះបញ្ចាំងឲ្យឃើញអំពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពេញលេញរបស់ **ឌុច** នឹងជួយជម្រុញដល់ការវិវត្តន៍ច្បាប់កម្ពុជា ព្រមទាំងផ្តល់សារៈសំខាន់ជានិមិត្តរូប សម្រាប់ប្រជាជនកម្ពុជានិងស្គាល់ភាពជាម្ចាស់លើដំណើរការនីតិវិធីតុលាកានេះ ។

កង្វះនីតិវិធីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលទ្ធភាពដែលអាចមានផលវិបាកជាអវិជ្ជមាន នៅក្នុងពេលសវនាការជំនុំជម្រះក្តី បាននាំឲ្យសហព្រះរាជអាជ្ញាសម្រេចចិត្តក្នុងការប្តឹងឧទ្ធរណ៍នេះ។ សហព្រះរាជអាជ្ញានឹងដាក់សារណាបណ្តឹងឧទ្ធរណ៍នៅមុនថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨នេះ តាមកាលកំណត់ច្បាប់។ បន្ទាប់ពីនោះ សហព្រះរាជអាជ្ញានឹងធ្វើការជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធរបស់តុលាការនេះ ដើម្បីជម្រុញឲ្យសម្រេចចាត់ការលើបណ្តឹងឧទ្ធរណ៍នេះឲ្យបានឆាប់ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨